www.ekasar.com

00214

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ005 សកបយ

ភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០០

សារាចរ
ស្តីពី
សិទ្ធិធ្វើកូដកម្ម

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានសង្កេតឃើញថា នារយៈពេលចុងក្រោយនេះ មានសកម្មភាពមិនប្រក្រតីមួយចំនួនបានកើតឡើងជាបន្តបន្ទាប់ ក្រោមការដឹកនាំរបស់អ្នកដឹកនាំសហព័ន្ធសហជីព និងសហជីពខ្លះ ។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា និងជំពូកទី១៣ នៃច្បាប់ស្តីពីការងារ កម្មករនិយោជិត មានសិទ្ធិធ្វើកូដកម្ម ប៉ុន្តែសិទ្ធិធ្វើកូដកម្មនេះ ត្រូវតែប្រតិបត្តិនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។ មាត្រា ៣១៨ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារ បានចែងថា " កូដកម្ម គឺជា ការឈប់ធ្វើការដោយកម្មករ និយោជិត ១ក្រុម ដែលមានការព្រមព្រៀងគ្នា ហើយបានធ្វើឡើងនៅក្នុងសហគ្រាសមួយ ឬ គ្រឹះស្ថានមួយ ក្នុងគោលបំណងដើម្បីទទួលបាននូវដំណោះស្រាយវិវាទចំពោះការទាមទាររបស់កម្មករនិយោជិត ពីនិយោជក ហើយក៏ជាល័ក្ខខ័ណ្ឌ ដើម្បីចូលធ្វើការវិញ " ។កូដកម្ម គឺជាការឈប់ធ្វើការងារ ដែលកម្មករនិយោជិត ត្រូវស្ថិតនៅក្នុងបរិវេណរោងចក្រ សហគ្រាស គ្រឹះស្ថាន ដើម្បីធ្វើការតវ៉ា ឬ ទាមទារអ្វីមួយ ពីនិយោជក ពោលគឺកូដកម្ម មិនមែនជាការនាំគ្នាដើរ ជាក្រុម ជាពួក ជាក្បួន ទៅទីកន្លែងផ្សេងៗនោះឡើយ ។

មាត្រា ៣២៣ នៃច្បាប់ស្តីពីការងារចែងថា " កូដកម្មត្រូវប្រកាសធ្វើតាមនីតិវិធីដែលមានកំណត់ក្នុងលក្ខន្តិកៈសហជីព ។ លក្ខន្តិកៈនេះ ត្រូវកំណត់អំពីការអនុម័តដោយការបោះឆ្នោតជាសម្ងាត់ ស្តីពីការសម្រេចអោយធ្វើកូដកម្ម "ពោលគឺ មុននឹងសំរេចធ្វើកូដកម្ម អ្នកដឹកនាំសហជីព ត្រូវធ្វើការប្រជុំ និងស្នើសុំការអនុម័តពី កម្មករ និយោជិត ដែលជា សមាជិករបស់ខ្លួន អំពីការធ្វើកូដកម្មនេះ បើកម្មករ និយោជិត មិនយល់ព្រមមិនឯកភាពទេ កូដកម្មនឹងមិនត្រូវប្រព្រឹត្តិឡើងទេ មិនមែនអ្នកដឹកនាំសហជីពសំរេចដោយចិត្តឯង ហើយទៅបំផុស ឬ បង្ខិតបង្ខំ បងប្អូនកម្មករ និយោជិត អោយធ្វើកូដកម្មឡើយ ។

មាត្រា៣២៤ នៃច្បាប់ស្តីពីការងារ បានចែង អំពី " ការជូនដំណឹងមុន " ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងតិច គិតតែថ្ងៃធ្វើការ មុននឹងធ្វើកូដកម្ម ពោលគឺបើសិនជាសមាជិក សហជីពអនុម័ត ឯកភាពធ្វើកូដកម្ម

www.ekasar.com

00215



នោះមុនពេលធ្វើកូដកម្មអ្នកដឹកនាំសហជីពត្រូវជូនដំណឹងទៅនិយោជករបស់ខ្លួន និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រយៈពេលយ៉ាងតិច ៧ ថ្ងៃ មុនធ្វើកូដកម្ម ។

មាត្រា៣៣០ នៃច្បាប់ស្តីពីការងារ បានចែងថា " កូដកម្មត្រូវប្រព្រឹត្តិទៅដោយសន្តិវិធី " ។

មាត្រា៣៣១ នៃច្បាប់ស្តីពីការងារ បានចែងថា " សេរីភាពនៃការធ្វើការងាររបស់អ្នកមិនមែនជាកូដករ ត្រូវបានការពារទល់និងការបង្ខិតបង្ខំ ឬ ការគំរាមកំហែង ផ្សេងៗ " ពោលគឺ កម្មករ និយោជិតដែលមិនចង់ចូលរួមធ្វើកូដកម្ម អាចនៅធ្វើការជាធម្មតាបាន គ្មានអ្នកដឹកនាំសហជីពណា ឬ ជនណា អាចបង្ខិតបង្ខំ គំរាមកំហែង អោយលុះតាមអំពើចិត្តរបស់ខ្លួនឡើយ ។

ចំពោះការធ្វើសកម្មភាពមិនប្រក្រតីកន្លងទៅ ដែលមានទ្រង់ទ្រាយជាបាតុកម្ម ដែលដឹកនាំដោយអ្នកដឹកនាំ សហព័ន្ធសហជីព និង សហជីព ខ្លះ នាអំឡុងពេលកន្លងមក គឺមិនបានអនុវត្តទៅតាមបទបញ្ញត្តិទាំងឡាយ នៃ ច្បាប់ស្តីពីការងារទេ ។

ចាប់ពីពេលនេះតទៅ អ្នកដឹកនាំ ឬ អភិបាល នៃអង្គការសហជីព និងសហព័ន្ធសហជីព ត្រូវអនុវត្ត " សិទ្ធិធ្វើកូដកម្ម " អោយបានត្រឹមត្រូវតាមច្បាប់ និង បទបញ្ញាស្តីពីការងារ ជាធំហិត ។ ជនប្រព្រឹត្តិល្មើសនឹងមាត្រាទាំងឡាយនៃច្បាប់ស្តីពីការងារ ត្រូវទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់នេះ និងបទបញ្ញត្តិ របស់រដ្ឋជាធរមាន ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អ្នកដឹកនាំសហជីព សហព័ន្ធសហជីព ព្រមទាំងបងប្អូនកម្មករ និយោជិត នឹងអនុវត្តបានត្រឹមត្រូវតាមច្បាប់ ស្តីពីការងារ ជាកុំខាន ។/

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូនៈ</u>

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត- ក្រុង " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
- សមាគមនិយោជក " ដើម្បីអនុវត្ត "
- សហព័ន្ធសហជីព " ដើម្បីអនុវត្ត "
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
- រាជកិច្ច
- កាលប្បវត្តិ និង ឯកសារ